# អនុស្សាវរីយ៍ភ្នំបាខែង

បទ កាកគតិ

- រសៀលតងភ្នំ ស្ដាប់រៃវាយំ លើភ្នំបាខែង
ឈរមើលថ្ងៃលិច កម្ដេចសូរ្យសែង សម្លឹងម្នាក់ឯង
មើលជើងមេឃឆ្ងាយ ។

- រសៀលល្ងាចទៅ ថ្ងៃលិចធ្លាក់ទៅ ជាប់ចិត្តជិតកាយ
ជើងមេឃក្រហម រារម្យពពកសាយ ហាក់ស្បើយសប្បាយ
ពេលមើលថ្ងៃលិច ។

- យប់យន់រាត្រី ព្រឺស្រៀវស្មារតី ចាំជាប់ជានិច្ច
យប់ធ្លាក់ជំនោរ វាយោរវិច ម្នាក់ឯងប្រឹងធ្មេច
ដេកលើអង្រឹង ។

- រាត្រីសែនស្ងាត់ ខ្យល់នៅតែផាត់ ដេកគិតរំពឹង
ទោះបីពេលយប់ សញ្ជប់សញ្ជឹង ទឹកស្ងើចព្រលឹង
គេរដូនតាខ្មែរ ។

- ឱ ! ភ្នំបាខែង ខ្ញុំនៅម្នាក់ឯង ដេកជិតចិតថៃ
រក្សាស្នាដៃ ថ្លាថ្លៃពូកែ ក្នុងចិត្តស្និទ្ធស្នេហ៍
ចាំជាប់ឱរា ។

ថ្ងៃទី ៣ សីហា ២០០២



និពន្ធដោយ ស៊ី ម៉ារទី សាស្ត្រាចារ្យសាកលវិទ្យាល័យភូមិន្ទកសិកម្ម

# ស្រះស្រង់

បទ កាកគតិ

- វេលាថ្ងៃត្រង់ មកដល់ស្រះស្រង់ ត្រជាក់ចិន្ដា
ក្លិនផ្កាក្រអូប ស្រូបចូលឱរា ឃើញផ្ទៃទឹកថ្លា
ហាក់ស្បើយក្នុងចិត្ត ។

- ជ្រកក្រោមម្លប់ឈើ ភ្នែកគយគន់មើល ស្រះស្រង់ប្រណីត
ចម្លាក់គោថ្ម ឈរត្រង់សណ្ឋិត គួរឱ្យស្នេហ៍ស្និទ្ធ
ផ្ចិតក្នុងរូបកាយ ។

- ម្លប់ឈើត្រឈៃ ត្រជាក់ប្រពៃ យើងផ្ដើមរៀបបាយ
ហូបបាយកញ្ចប់ គ្រប់គ្នាក្អាកក្អាយ ទឹកមុខស្រស់ស្រាយ
រីករាយជ្រះថ្លា ។

- ផ្ទៃទឹកស្រះស្រង់ យកដៃចូកក្បង់ ពុះលាងភក្ត្រា
ត្រជាក់ពេកក្រៃ ដូងចៃចេតនា ចិត្តស្និទ្ធស្នេហា
មិនចង់ឃ្លាតសោះ ។

ថ្ងៃទី ២៣ តុលា ២០០៣

# ឱ ! ប្រាសាទអកយំ

បទ ព្រហ្មគីតិ

- ឱ ! ប្រាសាទអកយំ    ដែលរូបខ្ញុំបានទៅដល់
ឃើញហើយព្រួយកង្វល់    សោយសោកសល់ដល់ស្នាដៃ ។
- បែកបាក់បាត់រូបរាង    ត្រូវផ្គរភ្លៀងរៀងរាល់ថ្ងៃ
ណាមួយចោរចង្រៃ    ចិត្តព្រៃផ្សៃគាស់យកថ្ម ។
- ជីកដីក្រោមប្រាសាទ    បាត់បង់ស្នាតលែងនៅល្អ
បំផ្លាញនៅបន្ត    ចោរអីក៏ចង្រៃម្ល៉េះ ។
- អាហើតអាណោចពេក    ចិត្តសង្វេគទ្រូងស្ទើរប្រេះ
មកពីយើងប្រហែស    យើងមិនចេះរួមការពារ ។
- សតវត្សរ៍ច្រើនកន្លង    ខ្មែរប្អូនបងសង្គ្រាមគ្នា
ដណ្តើមរាជភារា    ភ្លេចនឹកនាប្រាសាទខ្មែរ ។
- ឥឡូវសន្តិភាព    សូមជម្រាបញាតិមិត្តសែ
សូមជួយរក្សាថែ    ស្នាដៃខ្មែរបុរាណផង ។

ថ្ងៃទី ២៥ មីនា ២០០៣





# មាតាទៅភ្នំគូលែន

បទ ពាក្យប្រាំពីរ

- ជិះកាត់ព្រឹក្សព្រៃនៃដងផ្លូវ    មាតាតម្រូវទៅគូលែន
ធម្មជាតិព្រឹក្សាអស្ចារ្យមែន    ចិត្តសែនសប្បាយកាយរីករាយ ។
- ព្រៃព័ទ្ធពេញភ្នំធំសន្ធឹក    ព្រៃខ្ពស់ពន្លឺកញ្ចឹកពីនាយ
ព្រៃខៀវស្រងាត់សត្វស័ព្ទណាយ    មិនងាយឯណាថាបានមក ។
- ផ្លូវគ្រួសក្រហមល្មមមួយឡាន    ផ្កាព្រៃភ្នំផានប្រាណពន្លក
រាយរីករបង់ចង់បេះយក    ឃើញភ្លាមនឹកភ្ញកចិត្តចេតនា ។
- ផ្ទាំងថ្មតូចធំជុំសងខាង    ព្រៃស្រោងកោងកាងបិទវេហា
អាកាសត្រជាក់ឥតឧបមា    ចិន្តាសប្បាយកាយសុខសាន្ត ។
- សត្វចាបចេកចាចយំតាមផ្លូវ    សប្បាយពេកក្រៃនៅក្នុងឡាន
ផ្លូវភ្នំគូលែនត្រជាក់ប្រាណ    មិនស្មានថាបានមកដល់សោះ ។
- ទោះរយខែឆ្នាំចាំជានិច្ច    នឹកឃើញមិនភ្លេចចាំទាំងអស់
ទោះឃ្លាតទៅឆ្ងាយកាយអាឡោះ    នឹកដល់សម្រស់ភ្នំគូលែន ។

ថ្ងៃទី ២៣ តុលា ២០០២